ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសុខាភិបាល

លេខ...០៧០១ ស.ស.ម.ស.ប.ស

ថ្ងៃ ... ខែ ... ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣

រាជធានីភ្នំពេញ, ថ្ងៃទី ០៥ ខែ សីហា ឆ្នាំ២០១៩

# រដ្ឋមន្ត្រីក្រសួងសុខាភិបាល

ជម្រាបមក

លោក-លោកស្រីប្រធានមន្ទីរសុខាភិបាលរាជធានី - ខេត្ត

**កម្មវត្ថុ**: វគ្គបណ្តុះបណ្តាលអេពីដេមីសាស្ត្រអនុវត្តជួរមុខ (Frontline FETP)ឆ្នាំ ២០១៩ រយៈពេល៣ខែ ចំនួន ២០នាក់ សម្រាប់មន្ត្រីនៃមន្ទីរសុខាភិបាល- រាជធានីខេត្ត ស្រុកប្រតិបត្តិដែលបំពេញការងារទាក់ទង ទៅនឹងប្រព័ន្ធតាមដានជំងឺឆ្លង និងការឆ្លើយតបទៅនឹងជំងឺរាតត្បាត។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុខាងលើ ខ្ញុំសូមជម្រាបលោក-លោកស្រីប្រធានថា៖ នាយកដ្ឋានប្រយុទ្ធនឹងជំងឺឆ្លងរួមសហការជាមួយនឹងអង្គការសុខភាពពិភពលោក (WHO) និងមជ្ឈមណ្ឌលគ្រប់គ្រង និងបង្ការជំងឺសហរដ្ឋអាមេរិក (US CDC) ប្រចាំនៅកម្ពុជានឹងរៀបចំវគ្គបណ្តុះបណ្តាលអេពីដេមីសាស្ត្រអនុវត្តជួរមុខ ជំនាន់ទីមួយ (First Frontline FETP) មានរយៈពេល បីខែសម្រាប់ឆ្នាំ២០១៩នេះ។ វគ្គសិក្សានេះមានគោលបំណងអភិវឌ្ឍចំណេះដឹង និងជំនាញចាំបាច់ ដើម្បីពង្រឹងសមត្ថភាពដល់មន្ត្រីនៃមន្ទីរសុខាភិបាលរាជធានី-ខេត្ត និងស្រុកប្រតិបត្តិ ពិសេសជាសមាជិកនៃក្រុមឆ្លើយតបបន្ទាន់ (RRT) ដែលបំពេញការងារទាក់ទងនឹងប្រព័ន្ធតាមដានជំងឺឆ្លង និងការឆ្លើយតបទៅនឹងជំងឺរាតត្បាតក្នុងតំបន់របស់ខ្លួន ដើម្បីឆ្លើយតបបានទាន់ពេលវេលា។

ការសិក្សាមានរយៈពេល បីខែ ក្នុងនោះសិក្ខាកាមត្រូវរៀនទ្រឹស្តីចំនួន៣សប្តាហ៍ (១សប្តាហ៍ ក្នុង១ខែ) នៅនាយកដ្ឋានប្រយុទ្ធនឹងជំងឺឆ្លងនៃក្រសួងសុខាភិបាល និងចន្លោះពេលនៅសល់ត្រូវត្រឡប់ទៅកន្លែងធ្វើការនៅអង្គភាពដើមវិញដើម្បីហាត់រៀនអនុវត្តលំហាត់នៃវគ្គសិក្សាទាក់ទងនឹងការតាមដាន និងឆ្លើយតបទៅនឹងការរាតត្បាតនៃជំងឺដោយមានការអភិបាលពីក្រុមអភិបាលថ្នាក់ជាតិ។ ក្រោយពីបញ្ចប់ការបណ្តុះបណ្តាលមន្ត្រីទាំងនោះត្រូវត្រឡប់ទៅបម្រើការងារនៅអង្គភាពដើមវិញយ៉ាងតិចរយៈពេល **បីឆ្នាំ** ដើម្បីរួមចំណែកធ្វើឱ្យប្រសើរឡើងនៃការតាមដាន និងឆ្លើយតបទៅនឹងការរាតត្បាតនៃជំងឺ។

ចាប់ទទួលពាក្យសុំចូលរៀនចាប់ពីថ្ងៃផ្សាយដំណឹងនេះទៅរហូតដល់ថ្ងៃទី៤ ខែកញ្ញា ឆ្នាំ២០១៩ វេលាម៉ោង ០៥ ល្ងាច។ ក្រសួងសុខាភិបាលនឹងផ្តល់ដំណឹងដល់បេក្ខជន ដែលត្រូវ បានជ្រើសរើសឲ្យចូលសិក្សាខាងលើនៅដើម ខែកញ្ញា ឆ្នាំ២០១៩ខាងមុខនេះ។ កាលបរិច្ឆេទនៃការចូលរៀនវគ្គបណ្តុះបណ្តាលនេះគឺចាប់ផ្តើមពីថ្ងៃទី ៣០ ខែកញ្ញា ឆ្នាំ២០១៩ នៅនាយកដ្ឋានប្រយុទ្ធនឹងជំងឺ ឆ្លងនៃក្រសួងសុខាភិបាល។ រាល់ការចំណាយក្នុងការបណ្តុះបណ្តាលជាបន្ទុករបស់អង្គការសុខភាពពិភពលោក។

ចំពោះពាក្យសុំចូលរៀន និងព័ត៌មានផ្សេងៗសូមមើលគេហទំព័ររបស់នាយកដ្ឋានប្រយុទ្ធនឹងជំងឺឆ្លង (www.cdcmoh.gov.kh) និងតាមរយៈបណ្តាញសង្គម Facebook (https://www.facebook.com/pages/Cambodian-Applied-Epidemiology-Training-AET)

អាស្រ័យហេតុនេះ សូមលោក-លោកស្រីប្រធានជួយផ្សព្វផ្សាយនិងលើកទឹកចិត្តមន្ត្រីក្រោមឱវាទដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ឱ្យដាក់ពាក្យសុំចូលរៀនក្នុងវគ្គនេះកុំបីអាក់ខានឡើយ។

សូមលោក-លោកស្រីប្រធានទទួលនូវការរាប់អានដ៏ស្មោះអំពីខ្ញុំ។

ឧ.រដ្ឋមន្ត្រី

រដ្ឋលេខាធិការ

សាស្ត្រាចារ្យ អេង_ហួត